ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**ធនាគារជាតិ នៃ កម្ពុជា**

លេខ..........................................................

រាជធានីភ្នំពេញ ថ្ងៃទី១៣ ខែមីនា ឆ្នាំ២០១៧

## សេចក្តីប្រកាសព័ត៌មាន
## ស្តីពី ការដាក់ពិដានអត្រាការប្រាក់ឥណទាន

ដើម្បីរួមចំណែកគាំទ្រគោលនយោបាយរបស់រាជរដ្ឋាភិបាល ក្នុងការការពារផលប្រយោជន៍ប្រជាពលរដ្ឋ ជាពិសេសប្រជាពលរដ្ឋក្រីក្រ ទប់ស្កាត់បំណុលវ័ណ្ឌក និងកាត់បន្ថយភាពក្រីក្រ ការពារអតិថិជនពីការគិតការប្រាក់ក្នុងអត្រាខ្ពស់ពេកពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងជំរុញការប្រើប្រាស់ឥណទានឲ្យកាន់តែមានប្រសិទ្ធភាព តាមរយៈការផ្តល់ឥណទានពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដោយមានការប្រុងប្រយ័ត្នខ្ពស់ជាងមុន ធនាគារជាតិនៃកម្ពុជាសម្រេចដាក់ពិដានអត្រាការប្រាក់ទៅលើឥណទានដែលផ្តល់ឱ្យដោយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងប្រតិបត្តិករឥណទានជនបទទាំងអស់។

ពិដានអត្រាការប្រាក់ឥណទានមានកម្រិត ១៨% ក្នុងមួយឆ្នាំ ហើយនឹងត្រូវអនុវត្តចាប់ពីថ្ងៃទី១ ខែមេសា ឆ្នាំ២០១៧ នេះតទៅជាកំហិត។ ការដាក់ពិដានឥណទាននេះ គឺជាការដាក់កម្រិតអតិបរមានៃអត្រាការប្រាក់ឥណទាន ដែលគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងប្រតិបត្តិករឥណទានជនបទទាំងអស់ អាចកំណត់យកពីអតិថិជនដែលខ្ចីប្រាក់ពីគ្រឹះស្ថាន។ ចំពោះខ្លឹមសារលម្អិត សូមអានប្រកាសរបស់ធនាគារជាតិនៃកម្ពុជាលេខ ធ៧.០១៧.១០៩ ប្រ.ក ស្តីពីការដាក់ពិដានអត្រាការប្រាក់ឥណទាន ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០១៧។

សេចក្តីដូចបានជម្រាបជូនខាងលើ សូមសាធារណជនទាំងអស់មេត្តាជ្រាបជាព័ត៌មាន។

**ទំនាក់ទំនង ៖**
ផ្នែកទំនាក់ទំនង, ធនាគារជាតិនៃកម្ពុជា
ទូរស័ព្ទ ៖ (៨៥៥) ២៣ ៩៩០ ១៩៦
អ៊ីម៉ែល ៖ nbccommunication@nbc.org.kh